**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ៩៩៦ មស.សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការប្រើប្រាស់ក្រុម Telegram ថ្នាក់ដឹកនាំក្រសួងនិងអង្គភាពក្រោមឱវាទក្រសួង**
**និងនីតិវិធីនៃការផ្តល់ជូននូវលិខិតបញ្ជាបេសកកម្ម**

- យោងចំណារឯកភាពរបស់ឯកឧត្តមរដ្ឋមន្ត្រីចុះថ្ងៃទី២៤ខែមីនាឆ្នាំ២០១៦ លើរបាយការណ៍ស្តីពីលទ្ធផលនៃអង្គប្រជុំពិភាក្សាលើការងារចំពោះមុខរបស់ក្រុមអ្នកនាំពាក្យនិងក្រុមបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួងមុខងារសាធារណៈ។

ក្រសួងមុខងារសាធារណៈ សូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការស៊ីវិលក្រោមឱវាទក្រសួងទាំងអស់ជ្រាបថា ក្រសួងនឹងដាក់ឱ្យដំណើរការនូវក្រុម Telegram ថ្នាក់ដឹកនាំក្រសួងនិងអង្គភាពក្រោមឱវាទក្រសួង និងនីតិវិធីនៃការផ្តល់ជូននូវលិខិតបញ្ជាបេសកកម្ម ដូចខាងក្រោម៖

**ក.ការបង្កើតនិងដាក់ឱ្យដំណើរការនូវក្រុម Telegram ថ្នាក់ដឹកនាំក្រសួងនិងអង្គភាពក្រោមឱវាទក្រសួង**

១. សមាជិកក្រុម Telegram ថ្នាក់ដឹកនាំក្រសួងនិងអង្គភាពក្រោមឱវាទក្រសួង រួមមាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយក-នាយឧទ្ទកាល័យ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង នាយក-នាយករងសាលាភូមិន្ទរដ្ឋបាល អធិការ ប្រធាននាយកដ្ឋាន ប្រធានមជ្ឈមណ្ឌល ប្រធានអង្គភាពលទ្ធកម្ម និងប្រធានមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

២. ក្រុម Telegram ថ្នាក់ដឹកនាំក្រសួងនិងអង្គភាពក្រោមឱវាទក្រសួង គឺជាកន្លែងសម្រាប់ទទួលនិងផ្តល់ព័ត៌មានផ្លូវការរបស់ក្រសួងពាក់ព័ន្ធនឹងការអញ្ជើញចូលរួមក្នុងអង្គប្រជុំឬកម្មវិធីនានា ស្នើសុំឬផ្តល់អនុសាសន៍ផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួន និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ក្នុងន័យកាត់បន្ថយការប្រើប្រាស់ក្រដាសនិងលើកកម្ពស់សុខុមាលភាពមន្ត្រីរាជការ

៣. អង្គភាពនីមួយៗត្រូវបង្កើតក្រុម Telegram ឬ បច្ចេកវិទ្យាផ្សេងៗទៀត ដោយឡែកពីក្រុម Telegram ថ្នាក់ដឹកនាំក្រសួងនិងអង្គភាពក្រោមឱវាទក្រសួង ដើម្បីចែកចាយព័ត៌មានបន្តដល់មន្ត្រីរាជការក្រោមឱវាទអង្គភាពនីមួយៗ

៤. ហាមដាច់ខាតនូវរាល់ការដាក់បញ្ចូលនូវព័ត៌មានទាំងឡាយណា ដែលខុសពីតួនាទីនិងភារកិច្ចរបស់ក្រសួង ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ និង អង្គភាពក្រោមឱវាទក្រសួង។

**ខ.នីតិវិធីនៃការផ្តល់ជូននូវលិខិតបញ្ជាបេសកកម្ម**

១. ខុទ្ទកាល័យ ឬ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ជាអង្គភាពទទួលសិទ្ធិក្នុងការផ្តល់លិខិតបញ្ជាបេសកកម្ម

២. ការផ្តល់ជូននូវលិខិតបញ្ជាបេសកកម្មបាន លុះត្រាណាតែមានលិខិតអញ្ជើញពីអង្គភាពពាក់ព័ន្ធ ឬ មានគោលការណ៍ឯកភាពពីថ្នាក់ដឹកនាំក្រសួង

៣. ថ្នាក់ដឹកនាំ ឬ មន្ត្រីរាជការ ដែលត្រូវបានចាត់ឱ្យទៅបំពេញបេសកកម្មនានា ត្រូវផ្តល់មកវិញនូវលិខិតបញ្ជាបេសកកម្មទិដ្ឋាការចុះធ្វើដំណើរដែលមានព័ត៌មានគ្រប់គ្រាន់ និងរបាយការណ៍លទ្ធផលការងារ មកអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីចាត់ចែងបន្តទៅតាមនីតិវិធីជំនាញជាធរមាន។

ទទួលបានការណែនាំនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការស៊ីវិលក្រោមឱវាទក្រសួងទាំងអស់ អនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មីនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**